ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧២ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# លក្ខន្តិកៈសមាជិកបណ្ឌិតសភា នៃរាជបណ្ឌិតសភាកម្ពុជា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួល មាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៧/៣១០ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៧ ស្តីពីប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និងមន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាកម្ពុជា

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១ .-

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីលក្ខណៈសម្បត្តិ ការទទួលខុសត្រូវ និងសិទ្ធិរបស់សមាជិកបណ្ឌិតសភា ក្នុងការស្រាវជ្រាវវិស័យវប្បធម៌និងវិទ្យាសាស្ត្រ នៃរាជបណ្ឌិតសភាកម្ពុជា។

មាត្រា ២ .-

អនុក្រឹត្យនេះអនុវត្តចំពោះសមាជិកបណ្ឌិតសភាទាំងអស់ នៃរាជបណ្ឌិតសភាកម្ពុជា។

## ជំពូកទី ២

## លក្ខខណ្ឌ និងលក្ខណៈសម្បត្តិនៃសមាជិកបណ្ឌិតសភា

មាត្រា ៣ .-

សមាជិកបណ្ឌិតសភា ជាឥស្សរជនខាងចំណេះដឹង ឬជាបញ្ញវន្ត ដែលមានសញ្ញាបត្រចាប់ពីថ្នាក់បណ្ឌិតឡើងទៅ និងមានបទពិសោធន៍ច្រើនក្នុងការស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រ ព្រមទាំងមានស្នាដៃបោះពុម្ពផ្សាយនូវលទ្ធផលស្រាវជ្រាវរបស់ខ្លួនជាសាធារណៈ ឬជាអ្នកដែលបានជួយឧបត្ថម្ភចំពោះការពង្រីកវិស័យវប្បធម៌ និងវិទ្យាសាស្ត្រ ជាគុណប្រយោជន៍ដល់ប្រទេសកម្ពុជា។

មាត្រា ៤ .-

សមាជិកបណ្ឌិតសភានៃរាជបណ្ឌិតសភាកម្ពុជាមានបីប្រភេទ៖

-សមាជិកពេញសិទ្ធិ

-សមាជិកបម្រុង

-សមាជិកសមាគមិក និងសមាជិកកិត្តិយស។

ប្រភេទសមាជិកនីមួយៗ ត្រូវបានរៀបចំជាក្រុម។

មាត្រា ៥ .-

សមាជិកពេញសិទ្ធិអាចត្រូវបានជ្រើសរើសមិនលើសពី ៥នាក់ ក្នុងមួយឆ្នាំ ក្នុងចំណោមសមាជិកបម្រុងនៃរាជបណ្ឌិតសភាកម្ពុជា ដែលបានចូលជាសមាជិកបម្រុងយ៉ាងតិច ២ឆ្នាំ មានស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្របន្ត

ក្រោយពេលចូលជាសមាជិកបម្រុងយ៉ាងតិចចំនួន ២ឆ្នាំ ដែលទទួលស្គាល់ដោយរាជបណ្ឌិត្យសភាកម្ពុជា និងមានទំនាក់ទំនងការងារល្អនៅក្នុងរាជបណ្ឌិត្យសភាកម្ពុជា ។

មាត្រា ៦ .-

សមាជិកពេញសិទ្ធិ អាចមានចំនួនពី ៤០នាក់ ដល់ ៧០នាក់ ។ ចំនួនសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា ត្រូវមានប្រហាក់ប្រហែលគ្នា រវាងអ្នកឯកទេសមនុស្សសាស្ត្រ-វិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រ-បច្ចេកវិទ្យា តាមការរីកចម្រើនជាក់ស្តែងរបស់សង្គមជាតិ ។

មាត្រា ៧ .-

សមាជិកបម្រុងអាចត្រូវបានជ្រើសរើស មិនលើសពី ១០នាក់ក្នុងមួយឆ្នាំ ដោយក្រុមសមាជិកពេញសិទ្ធិ ក្នុងចំណោមបុគ្គលដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ ៖

១-បានដាក់ពាក្យសុំចូលជាសមាជិកបម្រុង

២-មានសញ្ញាបត្រចាប់ពីថ្នាក់បណ្ឌិតឡើងទៅ

៣-ជាអ្នកកំពុងបំពេញការងារនៅក្នុងស្ថាប័នរដ្ឋ ឬធ្លាប់បានបម្រើការងាររដ្ឋយ៉ាងតិច ២០ឆ្នាំ ហើយមានបទពិសោធន៍ការងារក្នុងឯកទេសរបស់ខ្លួនយ៉ាងតិច ១០ឆ្នាំក្រោយពេលទទួលបានសញ្ញាបត្របណ្ឌិត

៤-បានបោះពុម្ពស្នាដៃស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រជាសាធារណៈ យ៉ាងតិច ៣ ដែលទទួលស្គាល់ដោយរាជបណ្ឌិត្យសភាកម្ពុជា

៥-មានប្រវត្តិការងារល្អ និងមានសីលធម៌រស់នៅល្អ

៦-មិនដែលមានទោសឧក្រិដ្ឋ ឬមជ្ឈិមពីរឿងល្មើសប៉ះពាល់ទំនៀមទម្លាប់ កិត្តិយស និងភាពសុចរិត ។

មាត្រា ៨ .-

សមាជិកសមាគមិក និងសមាជិកកិត្តិយស ត្រូវជ្រើសរើសពីក្នុងចំណោមជនជាតិខ្មែរ និងជនជាតិបរទេស ដែលបានជួយឧបត្ថម្ភចំពោះការពង្រីកវិស័យវប្បធម៌និងវិទ្យាសាស្ត្រ ជាគុណប្រយោជន៍ដល់ប្រទេសកម្ពុជា ដោយក្រុមសមាជិកពេញសិទ្ធិ និងតាមសំណើពីសមាជិកពេញសិទ្ធិណាម្នាក់ ឬពីសាមីខ្លួន ដោយមានការធានាពីសមាជិកពេញសិទ្ធិ យ៉ាងតិចចំនួន ៣នាក់ ។

សមាជិកសមាគមិកត្រូវជ្រើសរើសក្នុងចំណោមអ្នកមានសញ្ញាបត្រចាប់ពីថ្នាក់បណ្ឌិតឡើងទៅ ។ សមាជិកកិត្តិយសត្រូវជ្រើសរើសពីមជ្ឈដ្ឋានអ្នកមានកិត្តិនាមល្បីល្បាញ ។

សមាជិកសមាគមិក និងសមាជិកកិត្តិយសមានចំនួនតាមការជាក់ស្តែង ។

បែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក និងសមាជិកកិត្តិយសត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ក្រុមសមាជិកបណ្ឌិតសភា ។

មាត្រា ៩ .-

សមាជិកពេញសិទ្ធិ និងសមាជិកបម្រុង ត្រូវតែងតាំងដោយអនុក្រឹត្យ ។

មាត្រា ១០ .-

សមាជិកសមាគមិក និងសមាជិកកិត្តិយសត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិ នៃរាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ១១ .-

សមាជិកបណ្ឌិតសភាទាំងបីប្រភេទស្ថិតនៅក្រោមការគ្រប់គ្រង របស់គណៈកម្មាធិការប្រតិបត្តិ នៃរាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ១២ .-

សមាជិកភាពនៃសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក និងសមាជិកកិត្តិយស នៃរាជបណ្ឌិតសភាកម្ពុជាត្រូវរលាយបាត់វិញ ដោយមរណភាព ដោយការសុំលាឈប់ ឬដោយត្រូវតុលាការផ្តន្ទាទោសពីបទល្មើសណាមួយដោយឥតព្យួរទោស ។

## ជំពូកទី ៣

## ការប្រជុំ និងជំនួបវិទ្យាសាស្ត្រ

មាត្រា ១៣ .-

ក្រុមសមាជិកពេញសិទ្ធិត្រូវប្រជុំប្រចាំត្រីមាស លើកលែងតែមានករណីចាំបាច់ដែលត្រូវប្រជុំវិសាមញ្ញ ។ របៀបវារៈនៃការប្រជុំផ្តោតលើការស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រ ជំនួបវិទ្យាសាស្ត្រ ផែនការការងារ របាយការណ៍សកម្មភាព ការវាយតម្លៃទទួលស្គាល់ស្នាដៃវិទ្យាសាស្ត្រ ការជ្រើសរើសសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក និងសមាជិកកិត្តិយស ។

មាត្រា ១៤ .-

ការប្រជុំចាត់ទុកជាបានការ លុះត្រាតែមានសមាជិកពេញសិទ្ធិចំនួនភាគច្រើនដាច់ខាត នៃចំនួនសមាជិកពេញសិទ្ធិដែលកំពុងបម្រើការនៅក្នុងប្រទេសចូលរួម ។ សេចក្តីសម្រេចត្រូវយកតាមសម្លេងភាគច្រើន នៃចំនួនអ្នកវត្តមាន ។ បើមានសម្លេងស្មើគ្នា សម្លេងប្រធានមានឧត្តមានុភាព ។

មាត្រា ១៥ .-

រាល់ការប្រជុំក្រុមសមាជិកពេញសិទ្ធិ សមាជិកបម្រុងអាចចូលរួមតាមការអញ្ជើញរបស់ប្រធាន និងមានសិទ្ធិផ្តល់យោបល់ ប៉ុន្តែ ពុំមានសិទ្ធិក្នុងការសម្រេច ។

មាត្រា ១៦ .-

ក្រុមសមាជិកពេញសិទ្ធិត្រូវរៀបចំជំនួបវិទ្យាសាស្ត្រយ៉ាងតិច ២ដង ក្នុងមួយឆ្នាំ ដើម្បីផ្សព្វផ្សាយនូវលទ្ធផលនៃការស្រាវជ្រាវ ឬរបមន្តថ្មី ឬគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រផ្សេងៗរបស់ខ្លួន ឬរបស់រាជបណ្ឌិតសភាកម្ពុជា។ ជំនួបវិទ្យាសាស្ត្រនេះ អាចមានការចូលរួមពីសមាជិកបណ្ឌិតសភាទាំងបីប្រភេទ មន្ត្រីស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រជាតិ និងអន្តរជាតិ។

មាត្រា ១៧ .-

ការចូលរួមក្នុងការប្រជុំក្រុមសមាជិកពេញសិទ្ធិ ឬក្នុងជំនួបវិទ្យាសាស្ត្រ ជាលក្ខខណ្ឌសម្រាប់អតីតភាពវិទ្យាសាស្ត្រ ក្នុងសមាជិកភាពពេញសិទ្ធិ។

## ជំពូកទី ៤
## ភារទទួលខុសត្រូវចំពោះវិស័យវិទ្យាសាស្ត្រ

មាត្រា ១៨ .-

ក្រុមសមាជិកពេញសិទ្ធិ និងក្រុមសមាជិកបម្រុង មានភារកិច្ចដូចខាងក្រោមនេះ ៖

១-រៀបចំគម្រោងផែនការអភិវឌ្ឍការងារស្រាវជ្រាវវិទ្យាសាស្ត្រ

២-បង្កើតស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រ

៣-ទទួលខុសត្រូវចំពោះស្នាដៃស្រាវជ្រាវរបស់មន្ត្រីស្រាវជ្រាវ

៤-ទទួលខុសត្រូវចំពោះលទ្ធផលស្រាវជ្រាវ ដែលកំពុងធ្វើការស្រាវជ្រាវ និងដែលពុំទាន់ធ្វើការផ្សព្វផ្សាយ

៥-ធ្វើសហប្រតិបត្តិការក្នុងការងារស្រាវជ្រាវវិទ្យាសាស្ត្រ ជាមួយស្ថាប័នជាតិ និងអន្តរជាតិ។

ភារកិច្ចទាំងនេះជាលក្ខខណ្ឌសម្រាប់អតីតភាពវិទ្យាសាស្ត្រ ក្នុងសមាជិកភាពពេញសិទ្ធិ និងសមាជិកភាពបម្រុង។

មាត្រា ១៩ .-

ក្រុមសមាជិកពេញសិទ្ធិមានភារកិច្ចទទួលខុសត្រូវរួមគ្នា ចំពោះការអភិវឌ្ឍការងារស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រ របស់រាជបណ្ឌិតសភាកម្ពុជា។

ក្រុមសមាជិកសមាគមិក និងក្រុមសមាជិកកិត្តិយស មានភារកិច្ចរួមចំណែកដល់ការងារស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រ និងឧបត្ថម្ភគាំទ្រដល់ការអភិវឌ្ឍ នៃរាជបណ្ឌិតសភាកម្ពុជា។

## ជំពូកទី ៥

## សិទ្ធិរបស់សមាជិកបណ្ឌិតសភា

មាត្រា ២០ .-

សមាជិកពេញសិទ្ធិមានឯករាជភាព ក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ។

លទ្ធផលនៃការស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា ដែលស្ថិតក្នុងផែនការរបស់រាជបណ្ឌិតសភាកម្ពុជា ជាកម្មសិទ្ធិរបស់រដ្ឋ ប៉ុន្តែ សមាជិកបណ្ឌិតសភាអាចទទួលបាននូវកម្រៃកម្មសិទ្ធិបញ្ញាពីស្នាដៃរបស់ខ្លួន។

មាត្រា ២១ .-

ការស្រាវជ្រាវត្រូវបានទទួលការគាំពារពីរដ្ឋ ក្នុងការការពារកម្មសិទ្ធិបញ្ញា ការបោះពុម្ពផ្សាយ ការចូលទៅកាន់ទីកន្លែងដែលជាកម្មវត្ថុនៃការស្រាវជ្រាវ ការការពារផ្នែកសន្តិសុខ និងសុវត្ថិភាពនៅទីកន្លែងជាកម្មវត្ថុនៃការស្រាវជ្រាវ និងការផ្តល់ធនធានសម្រាប់ការស្រាវជ្រាវ។

មាត្រា ២២ .-

សមាជិកពេញសិទ្ធិ និងសមាជិកបម្រុង ត្រូវទទួលបានប្រាក់បំណាច់ស្រាវជ្រាវដូចមានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៧០៧/៣១០ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៧ ស្តីពីប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និងមន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា។

មាត្រា ២៣ .-

សមាជិកពេញសិទ្ធិ ត្រូវទទួលបាននូវបុព្វសិទ្ធិ ដូចមានចែងក្នុងមាត្រា២២ រហូតអស់មួយជីវិត លើកលែងតែការសុំលាឈប់ ឬត្រូវតុលាការផ្តន្ទាទោស ដូចក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះ។

មាត្រា ២៤ .-

សិទ្ធិផ្សេងៗទៀតនឹងត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

មាត្រា ២៥ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ២៦ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងប្រធានរាជបណ្ឌិតសភាកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ